សុន្ទរកថារបស់ **ឯកឧត្តម គូម៉ាម៉ារ៉ូ យូជិ** ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព
របស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា
ថ្លែងក្នុងពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយ
សម្រាប់គម្រោងទ្រង់ទ្រាយតូចសន្តិសុខមនុស្សជាតិ របស់ប្រទេសជប៉ុន

១៦ មករា ២០១៤

**សូមគោរព ឯកឧត្តម ឯក សុនចាន់ រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម និងសិប្បកម្ម!**
**សូមគោរព ឯកឧត្តម កែន សត្ថា អភិបាលនៃគណៈភិបាលខេត្តកែប!**
**សូមគោរព លោក យស់ មុន្នី ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលខេត្តកែប!**
**សូមគោរព អស់លោក លោកស្រីភ្ញៀវកិត្តិយសទាំងអស់!**

ខ្ញុំមានសេចក្តីសោមនស្សរីករាយដើម្បីប្រារព្ធពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយរបស់ជប៉ុនសម្រាប់គម្រោងតំឡើងប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតក្នុងក្រុងកែប និងស្រុកដំណាក់ចង្អើរ ខេត្តកែប។ ជាបឋម ខ្ញុំសូមថ្លែងអំណរគុណចំពោះឯកឧត្តម ឯក សុនចាន់ និងឯកឧត្តម កែន សត្ថា ដែលបានអញ្ជើញមកចូលរួមក្នុងពិធីនេះ និងដើម្បីអបអរសាទគម្រោងនេះជាមួយគ្នា។

គម្រោងដែលមានថវិកាសរុប ១១២,៤២៣ ដុល្លាអាមេរិកមានគោលបំណងកែលម្អការទទួលបានទឹកស្អាតសម្រាប់ផឹកក្នុងតំបន់ពីរនៃខេត្តកែបដោយការតំឡើងប្រព័ន្ធចម្រោះទឹកដែលមានសមត្ថភាពអាចច្រោះទឹកបាន ២,៥០០លីត្រក្នុងមួយម៉ោង។ ទឹកស្អាតដែលត្រូវបានច្រោះដោយប្រព័ន្ធនេះនឹងត្រូវរក្សាទុកក្នុងបាសាំងស្តុកទឹកធំៗចំនួនបីដែលផ្តល់ជូនដោយគម្រោង និងសម្រាប់ចែកចាយដល់ប្រជាជនក្នុងមូលដ្ឋាន។

យើងសង្ឃឹមថាគម្រោងនេះនឹងផ្តល់ផលប្រយោជន៍ដល់ប្រជាជនជាង៨,៥០០នាក់ក្នុងមូលដ្ឋាន និងភ្ញៀវទេសចរណ៍ប្រមាណ៧៦០,០០០ដែលមកកំសាន្តក្នុងក្រុងកែបជារៀងរាល់ឆ្នាំដែលបច្ចុប្បន្ននេះពុំមានប្រព័ន្ធទឹកស្អាតសម្រាប់ប្រើប្រាស់ ព្រមទាំងដើម្បីដោះស្រាយបញ្ហាទឹកស្អាតសម្រាប់ពិសាររបស់ប្រជាជនក្នុងមូលដ្ឋានផងដែរ។ យើងក៏រំពឹងផងដែរថា ទឹកស្អាតនេះនឹងរួមចំណែកលើកស្ទួយអនាម័យ និងសុខុមាលភាពក្នុងមូលដ្ឋាន។

ការកែលម្អការទទួលបានទឹកស្អាតសម្រាប់ពិសារគឺជាតម្រូវការមូលដ្ឋានរបស់មនុស្សជាតិ ហើយក៏ជាគោលដៅមួយក្នុងចំណោមគោលដៅអភិវឌ្ឍន៍សហសវត្សរបស់កម្ពុជា។ ដោយមូលហេតុនេះ រដ្ឋាភិបាលជប៉ុនបានផ្តល់អាទិភាពខ្ពស់ទៅលើវិស័យនេះ ហើយបាន និងកំពុងបន្តគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជាតាំងពីឆ្នាំ១៩៩៣មកតាមរយៈការសាងសង់រោងចក្រផលិតទឹកស្អាត និងការផ្តល់កិច្ចសហប្រតិបត្តិការបច្ចេកទេសនៅក្នុងតំបន់ជាច្រើននៃប្រទេសកម្ពុជា។

ខ្ញុំសង្ឃឹមយ៉ាងមុតមាំថាគម្រោងដែលយើងបានចុះហត្ថលេខានៅថ្ងៃនេះនឹងត្រូវបានអនុវត្តដោយរលូន និងប្រកបដោយប្រសិទ្ធភាពដោយដៃគូរបស់យើងគឺមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលខេត្តកែប ហើយប្រព័ន្ធចម្រោះទឹកស្អាតនេះនឹងត្រូវបានប្រើប្រាស់ និងថែទាំយ៉ាងត្រឹមត្រូវដោយមានជំនួយពីអ្នកបច្ចេកទេសជប៉ុនដើម្បីប្រជាជនក្នុងតំបន់អាចទទួលបានអត្ថប្រយោជន៍កាន់តែយូរអង្វែងពីគម្រោងនេះ។

ជាចុងក្រោយនេះ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថាគម្រោងនេះនឹងជួយពង្រឹងជាបន្តទៅទៀតនូវទំនាក់ទំនងមិត្តភាពដែលមានស្រាប់រវាងប្រជាជនជប៉ុន និង ប្រជាជនកម្ពុជា។

សូមអរគុណ!